# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

១. **ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤។

២. **ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

៣. **ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣២រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៤៦រូប សរុបចំនួន៧៨រូប។

៤. **របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បទបង្ហាញស្តីពី"គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨" **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥. **សកម្មភាព និងលទ្ធផល ៖**

កិច្ចប្រជុំនេះមានគោលបំណង ដូចខាងក្រោម៖

៥.១ យល់ដឹងពី "គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ ឆ្នាំ២០២៣-២០២៨"

៥.២ ពង្រឹងការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យស្របនឹងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត។

៥.៣ ជំរុញអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត សម្រាប់ឆ្នាំ២០២៤ និងឆ្នាំ២០២៥។

ក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំ បានផ្តល់ពេលវេលាក្នុងការពិភាក្សា ផ្តល់មតិ និងអនុសាសន៍ដល់កិច្ចប្រជុំ ព្រមទាំងមានលទ្ធផលដូចខាងក្រោម៖

- ចក្ខុវិស័យរួមនៃគោលនយោបាយជាតិបញ្ចប់អេដស៍ គឺប្រជាពលរដ្ឋរស់នៅប្រកបដោយសុខុមាលភាព និងជៀសផុតពីមេរោគអេដស៍។
- គោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍ ដែលមានគោលបំណង៖
  ១- សម្រេចទប់ស្កាត់ការឆ្លងថ្មីឱ្យបានក្រោមមួយករណីក្នុងមួយថ្ងៃ តិចជាង២០០នាក់ក្នុងមួយឆ្នាំ។
  ២- សម្រេចទប់ស្កាត់ការស្លាប់ដោយសារអេដស៍ឱ្យបានក្រោម២០០នាក់ក្នុងមួយឆ្នាំ។
  ៣- លុបបំបាត់ការរើសអើងនិងមាក់ងាយអ្នកផ្ទុកមេរោគអេដស៍ឱ្យអស់ពីសង្គមកម្ពុជា និងមានវិធានចំនួន ៥៨ សម្រាប់អនុវត្ត។
- ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ ពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៦ ឆ្នាំ២០២៤-២០២៨ ផ្តោតសំខាន់លើផ្នែកបង្ការ។
- ពង្រីក និងពង្រឹងនូវសេវាថែទាំជំងឺអេដស៍ ដែលមកដល់បច្ចុប្បន្ន មានចំនួន៧៣កន្លែង (ត្រឹមត្រីមាសទី១ ឆ្នាំ២០២៤)។
- សកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ត្រូវចាប់ផ្តើមពីផ្ទៃក្នុងនៃក្រសួង ស្ថាប័ន ដោយអនុវត្តចាប់ពីអប់រំផ្សព្វផ្សាយមេរោគអេដស៍ និងវិធានការបង្ការដល់បុគ្គលិក មន្ត្រីរាជការ បន្តមកដល់ស្ថាប័ន និងវិស័យដែលមានចំណុះក្រសួង ស្ថាប័ន ដូចជា សហគ្រាស រោងចក្រ។ល។
- ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវជំរុញការផ្សព្វផ្សាយដល់ក្រុមគោលដៅអំពីការទទួលបានការធ្វើតេស្តរកមេរោគអេដស៍ ការទៅទទួលសេវាថែទាំជំងឺអេដស៍ និងការទទួលបាននូវប័ណ្ណមូលនិធិសមធម៌ សម្រាប់អ្នកផ្ទុកមេរោគអេដស៍។
- បានលើកឡើងពីការធ្វើផែនការសមិទ្ធកម្មនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលឆ្លើយតបទៅនឹងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចិរភាពកម្មវិធីអេដស៍សម្រាប់ ឆ្នាំ២០២៣-២០២៨។
- ត្រូវធ្វើផែនការសកម្មភាពថវិកាឆ្លើយតបនឹងមេរោគអេដស៍ ឱ្យបានទាន់ពេលវេលា។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំមានប្រសាសន៍ថា ត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយ

ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យចំលើការងារជាអាទិភាព។ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវអនុវត្តនូវផែនការសកម្មភាពថវិកាឆ្នាំ២០២៤ និងរៀបចំផែនការសកម្មភាពថវិកាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ឆ្នាំ២០២៥ ឱ្យទាន់ពេលវេលាតាមកាលបរិច្ឆេទហិរញ្ញវត្ថុ។

សម្រាប់កិច្ចប្រជុំបន្ទាប់នឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤។

ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំ បានជូនពរដល់សមាជិកអង្គប្រជុំសូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤

**បានឃើញ និងឯកភាព**

**ប្រធានអង្គប្រជុំ**

**បណ្ឌិត ឈឹម ឃិនដារ៉េត**

**បានពិនិត្យត្រឹមត្រូវ**

**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រកពជនជាន**

**វេជ្ជ. ហួត សេរីវង្ស**

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**